雲南日報
YUNNAN DAILY PRESS GROUP
云南日报报业集团
No.156

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

khmerlight@163.com
english.yunnan.cn

ឆ្នាំទី 26 លេខ 7658 ថ្ងៃសុក្រ ទី 15 ខែមិថុនា ឆ្នាំ 2018


## កម្មវិធី APP "ដើរលេងខេត្តយូនណាន" ត្រូវដាក់ឱ្យប្រើប្រាស់ជាផ្លូវការ




*ភ្ញៀវទេសចរម្នាក់កំពុងតែ ឆ្លងកាត់ច្រកទ្វារចូលភូមិយូនណាន ដែលជារមណីយដ្ឋានថ្នាក់ជាតិមួយ តាមរយៈប្រព័ន្ធទទួលស្គាល់អ្នកទេសចរ*

នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ ២០១៨ កម្មវិធីAPP "ដើរលេងខេត្តយូនណាន" ត្រូវបានដាក់ឱ្យសាកល្បងប្រើប្រាស់ជាផ្លូវការ។ កម្មវិធីAPPនេះគឺជាសមិទ្ធផលដំណាក់កាលទី១ នៃកម្មវិធី "ដើរលេងខេត្តយូនណានដោយប្រើប្រាស់ទូរស័ព្ទតែមួយគ្រឿង" ដែលជាប្រព័ន្ធព័ត៌មានវិទ្យាវៃឆ្លាតដែលរួមគ្នាច្នៃប្រឌិត និងបង្កើតដោយសាលារដ្ឋបាលខេត្តយូនណាននិងក្រុមហ៊ុនTENCENT ។

កម្មវិធី APP "ដើរលេងខេត្តយូនណាន" អាចផ្ដល់សេវាកម្មគ្រប់ប្រភេទដល់អ្នកទេសចរក្នុងការធ្វើទេសចរនៅខេត្តយូនណាន ។ មុននឹងទៅដើរលេងខេត្តយូនណាន អ្នកទេសចរអាចទិញសំបុត្រយន្តហោះ និងកក់បន្ទប់សណ្ឋាគារតាមរយៈកម្មវិធី APP នេះ ។ មិនតែប៉ុណ្ណោះអ្នកទេសចរអាចស្វែងរកព័ត៌មានផ្សេងៗអំពីទីដៅទេសចរណ៍ ព្រមទាំងទស្សនាមើលទិដ្ឋភាពជាក់ស្ដែងនៃតំបន់ទេសចរណ៍ផ្សេងៗនៅខេត្តយូនណាន ដោយប្រើប្រាស់កម្មវិធីនេះដើម្បីកំណត់ផែនការអំពីដំណើរទេសចររបស់ខ្លួន ។ នៅតំបន់ទេសចរណ៍ខ្លះអ្នកទេសចរអាចទិញសំបុត្រតាមរយៈកម្មវិធីAPP "ដើរលេងខេត្តយូនណាន" ជាមុនរួចចូលទៅលេងតាមរយៈការស្កេនមុខតែប៉ុណ្ណោះ ។ ក្រៅពីនេះ កម្មវិធី APP "ដើរលេងខេត្តយូនណាន" នេះនៅមានមុខងារជាច្រើនដូចជាធ្វើបទបង្ហាញអំពីតំបន់ទេសចរណ៍ជួយអ្នកទេសចររកបន្ទប់ទឹក បង់ថ្លៃផ្លូវល្បឿនលឿននិងណែនាំអំពីផលិតផលពិសេសតាមតំបន់ជាដើម ។ គួរបញ្ជាក់ថា ផលិតផលពិសេសដែលណែនាំដោយកម្មវិធីនេះសុទ្ធតែជាផលិតផលពិសេសរបស់ខេត្តយូនណានដែលទទួលបានការពិនិត្យយ៉ាងតឹងរ៉ឹងពីស្ថាប័នពាក់ព័ន្ធ ។ នៅពេលធ្វើដំណើរ មនុស្សយន្ត "កូនសណ្ដែក" នឹងអាចជួយទេសចរធ្វើផែនការដើរលេងតាមតម្រូវការជាក់ស្ដែងរបស់ពួកគេ ។

គួរបញ្ជាក់ថា អ្នកទេសចរដែលទៅដើរលេងខេត្តយូនណានអាចលើកយោបល់(ប្ដឹងឬតវ៉ា)ឱ្យស្ថាប័នពាក់ព័ន្ធតាមរយៈកម្មវិធីនេះរួមមានការលើកយោបល់អនឡាញការលើកយោបល់ជាសំឡេងនិងការលើកយោបល់តាមទូរស័ព្ទ។តាមរយៈកម្មវិធីនេះស្ថាប័នរដ្ឋាភិបាលអង្គភាពជំនាញនិងទេសចរអាចដាក់ពិន្ទុឱ្យសហគ្រាសផ្សេងៗលើវិស័យចំនួន៣ គឺស្តង់ដារគ្រប់គ្រងគុណភាពផលិតផលទេសចរណ៍ និងសេវាកម្ម ដើម្បីជាការវាយតម្លៃចំពោះអាជីវកម្មរបស់សហគ្រាសទេសចរណ៍និងជំរុញឱ្យសហគ្រាសពាក់ព័ន្ធផ្ដល់សេវាកម្មកាន់តែល្អប្រសើរ។ សព្វថ្ងៃប្រព័ន្ធកម្មវិធីនេះបានបញ្ចូលព័ត៌មាន និងវាយតម្លៃចំពោះសណ្ឋាគារចំនួនជាង៣.៥០០ភោជនីយដ្ឋានចំនួនជាង៤.០០០ទីភ្នាក់ងារទេសចរណ៍ចំនួនជាង៦៩០ និងមគ្គុទ្ទេសក៍ជាង៥.៣០០នាក់ ។៚ **ដោយជូ ហៃ**

## ខ្សែរថភ្លើងមីលឺ-ម៉ុងជឺបើកការដ្ឋានសាងសង់ជាផ្លូវការ

នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ ២០១៨ ខ្សែរថភ្លើងក្រុងមីលឺ-ម៉ុងជឺនៅខេត្តយូនណានបានបើកការដ្ឋានសាងសង់ជាផ្លូវការ។ ក្រោយពីខ្សែរថភ្លើងនេះត្រូវដាក់ឱ្យប្រើប្រាស់ជាផ្លូវការរយៈពេលនៃការធ្វើដំណើរពីក្រុងគុនមីងទៅក្រុងម៉ុងជឺនឹងអាចត្រូវបានកាត់បន្ថយដល់២ម៉ោងប៉ុណ្ណោះ។

តាមការឧទ្ទេសនាមបានឱ្យដឹងថា ខ្សែរថភ្លើងក្រុងមីលឺ-ម៉ុងជឺមានប្រភពពីស្ថានីយរថភ្លើងមីលឺនៅខាងជើង ហើយឆ្លងកាត់ក្រុងមីលឺ និងខាយយាន់រហូតដល់ក្រុងម៉ុងជឺ ។ ខ្សែរថភ្លើងនេះនឹងអាចក្លាយជាផ្នែកសំខាន់មួយនៃប្រព័ន្ធបណ្ដាញផ្លូវដែកអន្តរជាតិដែលចាត់ទុកក្រុងគុនមីង ជាស្នូលតាមរយៈការតភ្ជាប់ទៅនឹងខ្សែរថភ្លើងគុនមីង-យូស៊ី-ហាណូយ ដែលជាច្រកអន្តរជាតិចិន-វៀតណាម។ ខ្សែរថភ្លើងនេះមានប្រវែងសរុប១០៧គីឡូម៉ែត្រ ហើយមានផែនការសាងសង់រយៈពេលប្រាំមួយឆ្នាំ ។ រថភ្លើងអាចធ្វើដំណើរក្នុងល្បឿន២៥០គីឡូម៉ែត្រ/ម៉ោងតាមខ្សែរថភ្លើងនេះ ។

ខ្សែរថភ្លើងក្រុងមីលឺ-ម៉ុងជឺជាខ្សែរថភ្លើងសំខាន់មួយនៅភូមិភាគនិរតីចិន ដើម្បីធ្វើដំណើរទៅកាន់ប្រទេសវៀតណាម និងប្រទេសអាស៊ានផ្សេងៗទៀត។ ក្រោយពីបញ្ចប់ការសាងសង់ជាស្ថាពរខ្សែរថភ្លើងនេះនឹងអាចផ្ដល់ការងាយស្រួលដល់អ្នកដំណើរក្នុងការធ្វើដំណើរទៅមករវាងទីក្រុងសំខាន់នៅភូមិភាគកណ្ដាល និងអាគ្នេយ៍នៃខេត្តយូនណាន។ ជាពិសេស ខ្សែរថភ្លើងនេះនឹងអាចជំរុញ ឱ្យខ្សែរថភ្លើងខេត្តយូនណានតភ្ជាប់ ទៅនឹងខ្សែរថភ្លើងតំបន់អាស៊ីអាគ្នេយ៍ ព្រមទាំងមានសារសំខាន់ក្នុងការ បង្កើនការផ្លាស់ប្ដូរលើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការប្រាស្រ័យទាក់ទងគ្នារវាងប្រជាជននៃប្រទេសចិន និងតំបន់ អាស៊ីអាគ្នេយ៍ ។៚ **ដោយយៀ សៀវឈួង**




*សំណង់ផ្លូវរថភ្លើងចម្ងាយ ១០៧គីឡូម៉ែត្រពីទីក្រុងមីលឺទៅម៉ុងជឺ នៅភាគនិរតីយូនណាន ដែលបានចាប់ ផ្ដើមកសាងកាលពីថ្ងៃទី៣០ ខែឧសភា។ ផ្លូវនេះត្រូវគ្រោងឡើងនៅក្នុងល្បឿន ២៥០គីឡូម៉ែត្រនៅក្នុង១ម៉ោង (រូបថត ដោយ Li Hengqiang )*

## មជ្ឈមណ្ឌលផ្ដល់ទិដ្ឋាការប្រទេសអាហ្វ្រិក-ខាងត្បូងត្រូវបង្កើតនៅក្រុងគុនមីងនៃខេត្តយូនណាន

តាមប្រភពព័ត៌មានបានឱ្យដឹងថា សព្វថ្ងៃគេអាចស្នើសុំទិដ្ឋាការនៃប្រទេសអឺរ៉ុបចំនួនជាង១០ និងទិដ្ឋាការនៃប្រទេសកាណាដានៅក្រុងគុនមីង នៃខេត្តយូនណាន។ ឆ្នាំនេះ មជ្ឈមណ្ឌលផ្ដល់ទិដ្ឋាការប្រទេសអាហ្វ្រិកខាងត្បូងត្រូវបានបង្កើតឡើងនៅក្នុងទីក្រុងគុនមីង ដែលបានផ្ដល់ការងាយស្រួលដល់អ្នកក្រុងគុនមីង និងប្រជាជន ដែលរស់នៅក្បែរក្រុងគុនមីងក្នុងការស្នើសុំទិដ្ឋាការនៃប្រទេសអាហ្វ្រិកខាងត្បូង។

គិតមកដល់ពេលនេះគេអាចស្នើសុំទិដ្ឋាការនៃប្រទេសអូទ្រីស ហ្វាំងឡង់ ក្រិក ស៊ុយអែត អេស្ប៉ាញ បែលហ្ស៊ិក ក្រូអាស៊ី ឆែក ម៉ាល់ត៍ស្លូវេនី ឡេតូនី អេស្តូនី ប៉ូឡូញ លីទុយអានី អង់គ្លេស កាណាដា និងអាហ្វ្រិកខាងត្បូងនៅក្រុងគុនមីង។ ក្រៅពីនេះ សាលារដ្ឋបាលក្រុងគុនមីងកំពុងពិគ្រោះពិភាក្សាជាមួយប្រទេសផ្សេងៗនៅទ្វីបអាមេរិកខាងត្បូង និងអាហ្វ្រិកដើម្បីបង្កើតមជ្ឈមណ្ឌលផ្ដល់ទិដ្ឋាការនៅក្រុងគុនមីង។ អ្នកក្រុងគុនមីងអាចស្នើសុំទិដ្ឋាការនៃប្រទេសទាំងនោះក្នុងពេលឆាប់ៗខាងមុខ។៚

**ដោយតុង យូហុង**

## ស្ថាប័នគយក្រុងគុនមីងលុបចោលប្រព័ន្ធអាជ្ញាប័ណ្ណឆ្លងដែន

នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ ២០១៨ តាមការចាត់ចែងពីអគ្គនាយកដ្ឋានគយប្រទេសចិន ស្ថាប័នគយនៃក្រុងគុនមីង បានលុបចោលប្រព័ន្ធអាជ្ញាប័ណ្ណឆ្លងដែនអំពីទំនិញចេញចូលព្រំដែនចិន។

តាមការណែនាំបានឱ្យដឹងថា កាលពីមុនសហគ្រាសដែលនាំចេញនាំចូលផលិតផលដែលមានពាក់ព័ន្ធទៅនឹងការពិនិត្យជំងឺសត្វ និងរុក្ខជាតិត្រូវតែលើកសំណើសុំជូនឱ្យស្ថាប័នពិនិត្យជំងឺសត្វ និងរុក្ខជាតិ ដើម្បីទទួលបាននូវអាជ្ញាប័ណ្ណឆ្លងដែនទើបអាចប្រកាសជូនស្ថាប័នគយបាន។ ប៉ុន្តែក្រោយពីស្ថាប័នពិនិត្យជំងឺសត្វ និងរុក្ខជាតិត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធគយការកំណត់អំពីអាជ្ញាប័ណ្ណឆ្លងដែននេះ បានត្រូវកែទម្រង់ឱ្យកាន់តែមានភាពងាយស្រួល។ ការលុបចោលប្រព័ន្ធអាជ្ញាប័ណ្ណឆ្លងដែននេះ នឹងអាចសំចៃពេលវេលា និងកាត់បន្ថយនូវចំណាយនៃការបំពេញបែបបទឆ្លងដែនព្រម ទាំងផ្ដល់ការងាយស្រួលដល់ការធ្វើពាណិជ្ជកម្មអន្តរជាតិ។៚ **ដោយលីវ ជឺយូ**

## ខ្សែរថភ្លើងល្បឿនលឿនធ្វើឱ្យខេត្តយូនណានស្គាល់មិត្តល្អកាន់តែច្រើន



*រូបថតមួយសន្លឹកនៃរថភ្លើង ល្បឿនលឿនដែលកំពុងរត់ (រូបថតHu Xiaorong )*

នៅពេលព្រឹកថ្ងៃមួយនៃដើមរដូវក្ដៅលោកលីវប៉ាវ ហួ អ្នកភូមិដែលរស់នៅក្នុងភូមិរូងទេវតាឃុំភូជឺហឺខេត្តយូនណានកំពុងទទួលស្វាគមន៍ភ្ញៀវទី១ របស់លោក ។ លោកកាន់រំពាត់សេះយ៉ាងវែងហើយច្រៀងចម្រៀងដ៏ពីរោះជិះទេះសេះដឹកអ្នកដំណើរទៅកាន់ភូមិរូងទេវតា ។

ភូមិរូងទេវតាមានទីតាំងស្ថិតនៅក្នុងតំបន់ស្នូលនៃរមណីយដ្ឋានភូជឺហឺដែលជារមណីយដ្ឋានថ្នាក់ជាតិ ៥អា របស់ប្រទេសចិន ។ កាលពីមុនអ្នកភូមិនៅទីនោះរកស៊ីដោយធ្វើស្រែចម្ការនិងនេសាទត្រី ។ មុននឹងឆ្នាំ ១៩៩៣ អ្នកភូមិនៅទីនោះអាចបានចំណូលជាមធ្យមត្រឹមតែ៣០០ យ័នក្នុងរយៈពេលមួយឆ្នាំ ។

នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ២០១៦ ចំណតឃុំភូជឺហឺនៃខ្សែរថភ្លើងយូនណាន-ក្វាងស៊ីបានត្រូវបង្កើត និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការដែលបានជំរុញឱ្យកូនភូមិនេះដើរឆ្ពោះទៅកាន់យុគសម័យ "រថភ្លើងល្បឿនលឿន" ។ ខ្សែរថភ្លើងល្បឿនលឿនបានធ្វើឱ្យទេសចរកាន់តែច្រើនមានឱកាសទៅដើរលេងរមណីយដ្ឋានភូជឺហឺ ។ លោក លីវប៉ាវហួ បានប្រាប់អ្នកកាសែតដោយមានភាពសប្បាយរីករាយថា សព្វថ្ងៃខ្ញុំរកស៊ីដោយដឹកអ្នកដំណើរទៅដើរលេងហើយអាចបានចំណូលប្រហែល ៤០០-៥០០យាន់ក្នុងមួយថ្ងៃ ។

ផ្លូវដែកគឺជាសរសៃឈាមសំខាន់របស់សេដ្ឋកិច្ចនៃប្រទេសមួយ។ ក្នុងអំឡុងពេល៤០ឆ្នាំក្រោយពីអនុវត្តន៍គោលនយោបាយកែទម្រង់និងបើកទ្វារចំហហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសចិនបានត្រូវកែលម្អជាបន្តបន្ទាប់ ចំណែកខេត្តយូនណានក៏បានទទួលនូវសមិទ្ធផលដ៏ច្រើនគួរឱ្យកត់សម្គាល់ក្នុងការសាងសង់ខ្សែរថភ្លើង ។

នៅសតវត្សរ៍ទី២១ នេះរដ្ឋាភិបាលចិនបានផ្ដល់អាទិភាពដល់យុទ្ធសាស្ត្រនៃការអភិវឌ្ឍភូមិភាគខាងលិចនៃប្រទេសចិន ។ ខេត្តយូនណានបានកំណត់ផែនការអំពីការសាងសង់ផ្លូវដែក៨ ខ្សែចេញទៅខេត្តផ្សេងៗនិងផ្លូវដែក ៥ ខ្សែចេញទៅក្រៅប្រទេសដែលបានផ្ដល់កាលានុវត្តភាពដ៏ធំធេងដែលមិនធ្លាប់មានពីមុនសម្រាប់ការសាងសង់ប្រព័ន្ធបណ្ដាញផ្លូវដែកនៅខេត្តយូនណាន ។ នៅថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ២០១៦ ខ្សែរថភ្លើងសៀងហៃ-គុនមីង ខ្សែរថភ្លើងយូនណាន-ក្វាងស៊ីនិងខ្សែរថភ្លើងគុនមីង-យូស៊ីបានត្រូវដាក់ឱ្យប្រើប្រាស់នៅខេត្តយូនណានដែលបានធ្វើឱ្យខេត្តយូនណានឈានចូលទៅក្នុងយុគសម័យ "រថភ្លើងល្បឿនលឿន" ជាផ្លូវការ ។

ខេត្តយូនណានមានតំបន់ទេសចរណ៍ថ្នាក់ជាតិចំនួន២៣២ ហើយមានទីដៅទេសចរណ៍ល្បីឈ្មោះមួយចំនួនធំទាំងក្នុងប្រទេសចិន និងលើពិភពលោក រួមមានព្រៃថ្មហុងហឺ តាលីលីជាំង ស៊ីសាំងប៉ាននាធីងឈុង និងសាំងគ្រីឡាជាដើម។ ខ្សែរថភ្លើងល្បឿនលឿនបានផ្ដល់ការងាយស្រួលដល់អ្នកទេសចរក្នុងការធ្វើដំណើរទៅមករវាងខេត្តយូនណានជាមួយភាគខាងត្បូងខាងកើត និងខាងជើងនៃប្រទេសចិន ហើយបានធ្វើឱ្យប្រជាជនខេត្តយូនណានស្គាល់មិត្តល្អកាន់តែច្រើនឡើងៗ។៚